ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ជួយសម្របសម្រួលករណីពលរដ្ឋខ្មែរត្រូវឃាត់ខ្លួន ១០នាក់

******

ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ បានរាយការណ៍ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពីការសម្របសម្រួលបញ្ហាពាក់ព័ន្ធនឹងករណីពលករខ្មែរ១០នាក់ ដែលត្រូវឃាត់ខ្លួននៅ ស្រុកមឿងសាកែវ ខេត្តសាកែវ កាលពីថ្ងៃទី ១៤ ឧសភា ២០១៧ ពីបទឆ្លងដែនចូលកាប់ឈើគ្រញូងដោយខុសច្បាប់ ថា បន្ទាប់ពីបានទទួលបានព័ត៌មាន ថ្ងៃទី ១៤ ខែឧសភា ស្តីពីការឃាត់ខ្លួនពលរដ្ឋខ្មែរ ១០នាក់នេះ ស្ថានអគ្គកុងស៊ុលបានទំនាក់ទំនង ហើយទទួលបានការផ្តល់ព័ត៌មានពីអាជ្ញាធរស្រុកមឿងសាកែវ ដូចតទៅៈ

នៅថ្ងៃទី១៤ ឧសភា ២០១៧ ម៉ោងប្រមាណ ១២:០០ នាទី អាជ្ញាធរមូលដ្ឋានថៃសហការជាមួយកងកម្លាំងអភិរក្សព្រៃឈើនៃឧទ្យានជាតិប៉ាងស៊ីដា បានចុះល្បាតក្នុងតំបន់ឧទ្យានជាតិប៉ាងស៊ីដា ស្ថិតក្នុងភូមិណាយ ឃុំថាយែក ស្រុកមឿងសាកែវ ខេត្តសាកែវ បានប្រទះឃើញពលរដ្ឋខ្មែរប្រមាណ ១៥នាក់ កំពុងដើររកកាប់ឈើគ្រញូងនៅក្នុងតំបន់ឧទ្យានជាតិប៉ាងស៊ីដា ហើយឃាត់ខ្លួនបានចំនួន ១០នាក់ មានឈ្មោះដូចខាងក្រោម ព្រមទាំងវត្ថុតាងជាប់ខ្លួនមាន រណាយន្ត ស្បៀងអាហារ សម្ភារៈ និងសំលៀកបំពាក់មួយចំនួន ៖

| | | | | |
|---|---|---|---|---|
| ១. | ពេជ្រ ម៉ី | ភេទប្រុស | អាយុ ២៦ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ២. | សល់ ភា | ភេទប្រុស | អាយុ ៣៦ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៣. | ឈាវ ធី | ភេទប្រុស | អាយុ ២៣ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៤. | ទី អៀប | ភេទប្រុស | អាយុ ២៣ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៥. | ថន ធឿន | ភេទប្រុស | អាយុ ៣០ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៦. | វីន សល់ | ភេទប្រុស | អាយុ ២៧ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៧. | នេត្រ ផល្លា | ភេទប្រុស | អាយុ ៣០ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៨. | គឹម មឿន | ភេទប្រុស | អាយុ ២៥ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ៩. | ថុល ជាតិ | ភេទប្រុស | អាយុ ២៥ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |
| ១០. | វ៉េត អ៊ុន | ភេទប្រុស | អាយុ ៣០ ឆ្នាំ | ខេត្តបន្ទាយមានជ័យ |

បច្ចុប្បន្ន ពលរដ្ឋខ្មែរទាំង ១០ នាក់ ខាងលើ កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តសាកែវ រង់ចាំកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ស្ថានអគ្គកុងស៊ុល កំពុងបញ្ជូនមន្ត្រីកុងស៊ុលទៅជួបសាកសួរសុខទុក្ខពលរដ្ឋខ្មែរទាំង ១០នាក់នេះ ហើយនិងកំពុងសម្របសម្រួលជួយជំរុញដំណើរការកាត់ក្តីឲ្យបានឆាប់ និងត្រៀមផ្តល់មេធាវីជួយការពារក្តីជូនពួកគាត់។

ភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៧
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ